**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ: ១០៩៤ គ.ជ.ប

**ជម្រាបជូន**

**លោក គីម ឈន នាយកប្រតិបត្តិ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

**កម្មវត្ថុ ៖** ការពិនិត្យ សម្រេចលើការផ្តល់យោបល់ និងអនុសាសន៍លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

**យោង ៖**
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- លិខិតលេខ ១១២/២០២២ គបសយ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ របស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធមិនៅកម្ពុជា
- ស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

តាមកម្មវត្ថុ និងយោងខាងលើ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមថ្លែងអំណរគុណចំពោះ **គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា** ដែលបានយកចិត្តទុកដាក់ ពិនិត្យ ពិចារណា ផ្តល់ជាយោបល់ និងអនុសាសន៍លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

គ.ជ.ប បានធ្វើការសិក្សា ពិចារណាយ៉ាងហ្មត់ចត់ដោយផ្អែកលើច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធឯទៀត ហើយបានសម្រេចលើយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធមិនៅកម្ពុជា ដោយមានមូលហេតុដូចក្នុងតារាងជូនភ្ជាប់មកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក** ជ្រាបតាមការគួរ។

សូម **លោក** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃពុធ ៦ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះការផ្ដល់យោបល់របស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ) លើសេចក្ដីព្រាង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| **ជំពូកទី ១**<br>**បទប្បញ្ញត្តិទូទៅ** | | |
| ១.១០.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ | - **ស្នើសុំបន្ថែម ៖** ពង្រឹងនីតិវិធីឱ្យបានច្បាស់លាស់ទប់ស្កាត់លើសកម្មភាពទាំងឡាយដែលនាំឱ្យមានការភ័ន្តច្រឡំ ឬព្រួយបារម្ភ ឬនិងនាំឱ្យភិតភ័យចំពោះអ្នកបោះឆ្នោតមកបោះឆ្នោត តាមរយៈការស្នាក់ហៅមកកត់ឈ្មោះអ្នកបោះឆ្នោត ឬពាក្យសម្ដីពីជនដែលគ្មានភារកិច្ច ឬតម្រូវដោយនីតិវិធីនៅខាងក្នុង ឬក្រៅបរិវេណ និងនៅតាមដងផ្លូវនៃភូមិ។<br>- **មូលហេតុ ៖** ការកត់ឈ្មោះ ឬប្រើពាក្យសម្ដីពីជនដែលមិនមានតួនាទីក្នុងដំណើរការបោះឆ្នោត វាបានបង្កឱ្យមានការព្រួយបារម្ភចំពោះប្រជាពលរដ្ឋ ក្នុងការសម្រេចឆន្ទៈរបស់ខ្លួនតាមរយៈការបោះឆ្នោត។ | រក្សាទុកដដែល។<br>ខ្លឹមសារនេះ មានន័យគ្រប់គ្រាន់សម្រាប់អនុវត្ត។ |
| ១.១០.១៩ ត្រួតពិនិត្យចំណូល និងចំណាយក្នុងរយៈពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ។ | - **ស្នើសុំកែ ៖** នៅក្នុងរយៈពេលឃោសនាបោះឆ្នោត គ.ជ.ប មិនត្រឹមតែត្រួតពិនិត្យចំណូលចំណាយរបស់បេក្ខជន និងគណបក្សនយោបាយតែប៉ុណ្ណោះទេ គ.ជ.ប ត្រូវតែធានាស្មើភាពគ្នានៃការចំណាញ (ចំណាយ) ថវិកាក្នុងការឃោសនាបោះឆ្នោតគ្រប់គណបក្សនយោបាយនីមួយៗ និងដោយមិនលម្អៀង។ | រក្សាទុកដដែល។<br>អនុលោមតាមចំណុចទី១៧ កថាខណ្ឌទី៣ មាត្រា ៤២ នៃ ច.គ.ជ.ប ។<br>មាត្រា ៨៨ នៃ ច.ប.ត.រ ចែងថា "ការចំណាយរបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់"។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - **មូលហេតុ ៖** ការកំណត់ការត្រួតពិនិត្យការចំណូលចំណាយមិនទាន់គ្រប់គ្រាន់តាមគោលការណ៍ដើម្បីធានាស្មើភាពគ្នា និងតម្លាភាពនោះទេ ការកំណត់នូវនីតិវិធីនៃការចំណាយជាគោលការណ៍មួយជម្រុញឱ្យគ្រប់គណបក្សនយោបាយរឹតតែធានាស្មើភាព និងតម្លាភាព។ | |
| ១.១០.២៤ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត។ | - **ស្នើសុំកែ ៖** ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត...។ ចំណុចនេះ **<u>ត្រូវចែងឱ្យបានច្បាស់លាស់លើកជាគោលការណ៍ណែនាំដល់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ក្នុងការបើកផ្លូវឱ្យគ្រប់ភាគីពាក់ព័ន្ធមានលទ្ធភាពចូលរួមក្នុងការងារអប់រំប្រជាពលរដ្ឋ។</u>**<br>- **មូលហេតុ ៖** ការមិនបានចែងគោលការឱ្យបានច្បាស់លាស់បានផ្ដល់ឱ្យនូវលទ្ធភាពបកស្រាយមួយដោយកាត់បន្ថយការចូលរួមរបស់ភាគីពាក់ព័ន្ធ រួមទាំងការបកស្រាយដែលនាំឱ្យមានភាពភ័ណ្ឌច្រឡំទៀតផង។ | រក្សាទុកដដែល។<br>អនុលោមតាមចំណុចទី២១ កថាខណ្ឌទី៣ មាត្រា ៤២ នៃ ច.គ.ជ.ប ។<br>គ្រប់កម្មវិធីអប់រំ ផ្សព្វផ្សាយរបស់ភាគីពាក់ព័ន្ធត្រូវតែសុំការអនុញ្ញាតពី គ.ជ.ប និងអាជ្ញាធរមានសមត្ថកិច្ច។ |
| ១.១០.២៨ សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត លើកលែងតែបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។ | - **ស្នើសុំកែ ៖** នៅក្នុងចំណុចនេះ គ.ជ.ប ត្រូវគ្រប់គ្រង និងមិនគួរឱ្យមានការពង្រីកការអនុវត្តច្បាប់ ដែលអនុញ្ញាតឱ្យអាជ្ញាធរយកកំហុសនៃការបំពេញលក្ខខណ្ឌ ដែលបានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ទៅប្ដឹងទៅតុលាការក្នុងទោសព្រហ្មទណ្ឌនោះទេ។<br>- **មូលហេតុ ៖** កំហុសឆ្គង និងបទល្មើសត្រូវបានចែងក្នុងច្បាប់បោះឆ្នោតរួចហើយ។ ការកំណត់ព្រំដែននៃបណ្ដឹងគឺជាវិធានមួយ ដែលអាចជួយកាត់បន្ថយបញ្ហាបដិវាទ (Controversy) អំពីដាក់ទោស សិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពក្នុងជីវភាពនយោបាយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងការបកស្រាយដោយទូលំទូលាយ។ | រក្សាទុកដដែល។<br>អនុលោមតាមចំណុចទី២៥ កថាខណ្ឌទី៣ មាត្រា ៤២ នៃ ច.គ.ជ.ប ។<br>អនុលោមតាមមាត្រា ១៦៥ នៃ ច.ប.ត.រ ចែងថា ដំណើរការនីតិវិធី ដើម្បីចេញសេចក្ដីសម្រេចរបស់ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិ ដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|---|
| ១.១៩ | ប្រព័ន្ធជ្រើសរើសសមាសភាព គធ.ខប គឃ.សប និង គ.ក.ប ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។... | - **ស្នើសុំកែ** ៖ ការដាក់បេក្ខនារីក្នុងប្រព័ន្ធជ្រើសរើសសមាជិក និងបុគ្គលិកនៃ គធ.ខប គឃ.សប និងសមាសភាព គ.ក.ប ក្នុងប្រការនេះជាការប្រសើរ ប៉ុន្តែ **ក៏ត្រូវមានគោលការណ៍ឱ្យបានច្បាស់កំណត់ក្នុងនីតិវិធីក្នុងជ្រើសរើសសមាសភាពមន្ត្រី ដោយលើកទឹកចិត្តជាសមភាពយេនឌ័រផងដែរ។**<br>- **មូលហេតុ** ៖ ការមិនមានគោលការលើកទឹកចិត្តច្បាស់លាស់ដែលចែងក្នុងគោលការ នោះស្ត្រីត្រូវបានគេមិនផ្តល់ឱកាសជាពិសេសរវាងបេក្ខជនជាបុរស និងស្ត្រីដែលមានសមត្ថភាពស្មើគ្នា ឬក្រោមបន្តិចបន្តួចនោះ។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>លក្ខខណ្ឌជ្រើសរើសរបស់ គ.ជ.ប បានលើកទឹកចិត្តដល់ស្ត្រីរួចហើយ។ |
| ១.២៥ | គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការបោះឆ្នោត... | - **ស្នើសុំបន្ថែម** ៖ គ.ជ.ប ត្រូវធ្វើការជូនដំណឹង និងសម្របសម្រួលជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការបង្កភាពងាយស្រួលដល់ការអនុវត្តសកម្មភាពស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតរបស់អង្គការសង្គមស៊ីវិលដែលបានទទួលស្គាល់ដោយ គ.ជ.ប។<br>- **មូលហេតុ** ៖ គ.ជ.ប ជាស្ថាប័នទទួលខុសត្រូវលើការបោះឆ្នោត និងជាស្ថាប័នឯករាជ្យ។ អាជ្ញាធរ ជាអ្នកចូលរួមពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ជូន គ.ជ.ប។<br>ឧ. ករណីអ្នកសង្កេតការណ៍ខុមហ្វ្រែល ការបោះឆ្នោតឆ្នាំកន្លងមក តែងមានអាជ្ញាធរមូលដ្ឋានប្រើប្រាស់សិទ្ធិហាមឃាត់ការជ្រើសរើស និងមិនបង្កភាពងាយស្រួលក្នុងការបណ្តុះបណ្តាល សម្រាប់អ្នកសង្កេតការណ៍ចូលរួមសង្កេតទោះបីមានការសម្របសម្រួលពី គធ.ខប ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្លួនក៏ដោយ។ | រក្សាទុកដដែល។<br>គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងសហការជាមួយអាជ្ញាធរក្នុងការសម្របសម្រួលឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល។ |
| ១.២៦ | ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត... | - **ស្នើសុំបន្ថែម** ៖ គ.ជ.ប ត្រូវធ្វើការជូនដំណឹង និងសម្របសម្រួលជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការបង្កភាពងាយស្រួលដល់ការអនុវត្តសកម្មភាពស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតរបស់អង្គការសង្គមស៊ីវិលដែលបានទទួលស្គាល់ដោយ គ.ជ.ប ។ | រក្សាទុកដដែល។<br>គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងសហការជាមួយអាជ្ញាធរក្នុងការសម្របសម្រួលឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - **មូលហេតុ** ៖ គ.ជ.ប ជាស្ថាប័នទទួលខុសត្រូវលើការបោះឆ្នោត និងជាស្ថាប័នឯករាជ្យ។ អាជ្ញាធរ ជាអ្នកចូលរួមពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់ជូន គ.ជ.ប ។<br>ឧ. ករណីអ្នកសង្កេតការណ៍ខុមហ្វ្រែល ការបោះឆ្នោតឆ្នាំកន្លងមក តែងមានអាជ្ញាធរមូលដ្ឋានប្រើប្រាស់សិទ្ធិហាមឃាត់ការជ្រើសរើស និងមិនបង្កភាពងាយស្រួលក្នុងការបណ្ដុះបណ្ដាល សម្រាប់អ្នកសង្កេតការណ៍ចូលរួមសង្កេតទោះបីមានការសម្របសម្រួលពី គធ.ខប ក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្លួនក៏ដោយ។ | |
| **ជំពូកទី ៣**<br>**ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន** | | |
| ៣.១.២ ការផ្ដល់ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ គឺសម្រាប់សង្កេតមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ | - **ស្នើសុំបន្ថែម** ៖ ការផ្ដល់ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ គឺសម្រាប់សង្កេតមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត *និងកិច្ចការប្រតិបត្តិការរបស់ គឃ.សប ខធ.ខប និង គ.ជ.ប ទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។*<br>- **មូលហេតុ** ៖ ភ្នាក់ងារគណបក្សនយោបាយ គឺជាភាគីពាក់ព័ន្ធសំខាន់ក្នុងដំណើរការបោះឆ្នោត។ ម្យ៉ាងការបោះឆ្នោតដែលសេរី និងយុត្តិធម៌ត្រូវតែយកចិត្តទុកដាក់ពីតម្លាភាព និងសុចរិតភាពនៃដំណើរការបោះឆ្នោតទាំងមូល រួមទាំងកិច្ចប្រតិបត្តិការទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។ | រក្សាទុកដដែល។<br>ក្នុងជំពូកទី ៣ នៃ ច.ប.ត.រ កំណត់អំពីភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ក្នុងការសង្កេតមើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។ ចំណែកកិច្ចប្រតិបត្តិការនៅ គឃ.សប គធ.ខប គ.ជ.ប គណបក្សនយោបាយអាចចាត់តំណាងរបស់ខ្លួនចូលរួមតាមការស្នើសុំ និងអនុញ្ញាតពី គឃ.សប គធ.ខប និង គ.ជ.ប ។ |
| ៣.១.១០.២ លិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់សាមីពាក់ព័ន្ធជាបុគ្គល ឬជាបញ្ជី ដែលបញ្ជាក់ថាភ្នាក់ងារនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់សាមីពាក់ព័ន្ធនោះ ១ (មួយ) ច្បាប់។ | - **ស្នើសុំកែ** ៖ លិខិតបញ្ជាក់នេះត្រូវតែចេញដោយ *គឃ.សប*។<br>**មូលហេតុ** ៖ គឃ.សប អាចបំពេញកិច្ចការនេះបានល្អប្រសើរជាងមេឃុំ ចៅសង្កាត់ ម្យ៉ាងទៀត គឃ.សប ជាអ្នកកាន់កាប់បញ្ជីឈ្មោះស្រាប់ ហើយអាចមិនប៉ះពាល់សិទ្ធិចូលរួម។ | រក្សាទុកដដែល។<br>អនុលោមតាមមាត្រា៦៤ នៃ ច.ប.ត.រ បញ្ជីបោះឆ្នោតផ្លូវការត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ ដើម្បីទុកជាឯកសារផ្លូវការ ។ ដូចនេះអាជ្ញាធរអចិន្ត្រៃយ៍នៅមូលដ្ឋានឃុំ សង្កាត់នីមួយៗ ដែលមានសមត្ថកិច្ចគ្រប់គ្រង និងផ្ដល់លិខិតយថាភូតបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ គឺមានតែអាជ្ញាធរនៃឃុំ សង្កាត់សាមីតែប៉ុណ្ណោះ ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| ៣.១.១៦ ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយមានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ | - **ស្នើសុំបន្ថែម** ៖ ការផ្តល់ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយមានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត *រួមទាំងកិច្ចប្រតិបត្តិការរបស់ គឃ.សប ខធ.ខប និង គ.ជ.ប ទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។*<br>- **មូលហេតុ** ៖ ភ្នាក់ងារគណបក្សនយោបាយ គឺជាភាគីពាក់ព័ន្ធសំខាន់ក្នុងដំណើរការបោះឆ្នោត។ ម៉្យាងការបោះឆ្នោតដែលសេរី និងយុត្តិធម៌ត្រូវតែយកចិត្តទុកដាក់ពីតម្លាភាព និងសុចរិតភាពនៃដំណើរការបោះឆ្នោតទាំងមូល រួមទាំងកិច្ចប្រតិបត្តិការទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។ | រក្សាទុកដដែល។<br>ក្នុងជំពូកទី ៣ នៃ ច.ប.ត.រ កំណត់អំពីភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ក្នុងការសង្កេតមើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។ ចំណែងកិច្ចប្រតិបត្តិការនៅ គឃ.សប គធ.ខប គ.ជ.ប គណបក្សនយោបាយអាចចាត់តំណាងរបស់ខ្លួនចូលរួមតាមការស្នើសុំ និងអនុញ្ញាតពី គឃ.សប គធ.ខប និង គ.ជ.ប ។ |
| ៣.១.១៨.៦ មានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។ | - **ស្នើសុំបន្ថែម** ៖ មានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) *នៅការិយាល័យរាប់សន្លឹកឆ្នោត។*<br>- **មូលហេតុ** ៖ ភ្នាក់ងារគណបក្សនយោបាយ គឺជាភាគីពាក់ព័ន្ធសំខាន់ក្នុងដំណើរការបោះឆ្នោត។ ម៉្យាងការបោះឆ្នោតដែលសេរី និងយុត្តិធម៌ត្រូវតែយកចិត្តទុកដាក់ពីតម្លាភាព និងសុចរិតភាពនៃដំណើរការបោះឆ្នោតទាំងមូល រួមទាំងកិច្ចប្រតិបត្តិការទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។ | រក្សាទុកដដែល។<br>ភ្នាក់ងារគណបក្សនយោបាយ អាចថតរូបភាព ឬចម្លងតួលេខពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដែលបានបិទផ្សាយនៅមុខការិយាល័យរាប់សន្លឹកឆ្នោត។<br>ការអនុវត្តក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ តាមសេចក្តីសម្រេចរបស់ គ.ជ.ប ឆ្នាំ២០២២។ |
| ៣.២.៣ អ្នកសង្កេតការណ៍ជាតិចល័ត សំដៅលើថ្នាក់ដឹកនាំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។ | - **ស្នើសុំបន្ថែម** ៖ អ្នកសង្កេតការណ៍ចល័ត សំដៅលើថ្នាក់ដឹកនាំ ឬមន្ត្រី ឬបុគ្គលិក ឬអ្នកមានឈ្មោះក្នុងបញ្ជីស្នើសុំដោយស្ថាប័ន។<br>- **មូលហេតុ** ៖ សមាសភាពអ្នកសង្កេតការណ៍ជាតិចល័តគួរត្រូវបានចាត់ចែង និងកំណត់ដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ។ ក្រៅពីថ្នាក់ដឹកនាំសមាគម ឬអង្គការក៏មានបុគ្គលិកជំនាញ ឬមន្ត្រីដែលចាត់តាំងដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចុះសង្កេតដំណើរការបោះឆ្នោត ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់អ្នកសង្កេតការណ៍របស់ខ្លួននៅតាមការិយាល័យបោះឆ្នោត។ | យល់ព្រមតាមសំណើដោយកែសម្រួល ៖<br>អ្នកសង្កេតការណ៍ជាតិចល័ត សំដៅលើថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| ៣.៣ គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុនអំពីប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោត រហូតដល់ ១០ (ដប់) ថ្ងៃមុនថ្ងៃបោះឆ្នោត។ | - **ស្នើសុំកែ ៖**<br>- គ.ជ.ប ត្រូវធ្វើ...។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោតរហូតដល់ ៣ (បី) ថ្ងៃមុនថ្ងៃបោះឆ្នោត។<br>- ស្នើឱ្យប្រការនេះ ត្រូវដំណើរអនុវត្តនៅត្រឹម គធ.ខប<br>- **មូលហេតុ ៖** ដើម្បីឱ្យសមាគម ឬអង្គការមានពេលវេលាបន្ថែមទៀតក្នុងការជ្រើសរើសអ្នកសង្កេតការណ៍របស់ខ្លួន។ ម្យ៉ាងទៀតការសម្រេចផ្តល់កាតអ្នកសង្កេតការណ៍ជូនដល់អង្គការសង្គមស៊ីវិលត្រឹម គធ.ខប វាកាត់បន្ថយការងារច្រើនរបស់ គ.ជ.ប និងពន្លឿនការចេញ រួមទាំងបង្កើនប្រសិទ្ធិភាពការងារថែមទៀត។ | រក្សាទុកដដែល។<br>គ.ជ.ប បានកំណត់ក្នុងប្រតិទិនរួចហើយ។ |
| ៣.៣.១.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន។ | - **ស្នើសុំលុប ៖** ចំណុចនេះស្នើ គ.ជ.ប គួរតែលុបចេញពីមាត្រានេះ។<br>- **មូលហេតុ ៖** ការរាយការណ៍ពីផែនការថវិកា វាមិនមែនជាចំណុចចាំបាច់ដែល គ.ជ.ប ត្រូវលើកយកជាលក្ខខណ្ឌចាំបាច់នៅក្នុងការសុំសិទ្ធិចូលរួមសង្កេតការណ៍នោះទេ។ ការរៀបចំព័ត៌មានពីស្ថានភាពថវិកា វាពាក់ព័ន្ធជាមួយការកៀរគរធនធាននៃការចូលរួមដែលនាំឱ្យព័ត៌មានអាចមិនបានត្រឹមត្រូវ។ ម្យ៉ាងទៀត អង្គការសង្គមស៊ីវិលបានទទួលកាតព្វកិច្ចចំពោះមុខក្រសួងមហាផ្ទៃក្នុងការរាយការណ៍នេះហើយ។ | រក្សាទុកដដែល។<br>ស្ថានភាពថវិកាក្នុងចំណុចនេះ សំដៅលើបន្ទុកចំណាយរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចប្រតិបត្តិការសង្កេតការណ៍របស់ខ្លួន។ |
| **ជំពូកទី ៤**<br>**ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** | | |
| ៤.៥.៣ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់មណ្ឌលតែមួយគត់។ បេក្ខជនដែលមានឈ្មោះ | - **ស្នើសុំបន្ថែម ៖** *គ.ជ.ប ត្រូវមានសេចក្តីជូនដំណឹងដល់បេក្ខជន ក្នុងករណីដែលមើលឃើញថា ឈ្មោះរបស់* | រក្សាទុកដដែល។<br>អនុលោមតាមមាត្រា ២៩ នៃ ច.ប.ត.រ។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| ក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌលនឹងត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ទោះជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ។ | *បេក្ខជននោះមានក្នុងបញ្ជីឈរឈ្មោះលើពីមួយមណ្ឌល ដើម្បីឱ្យគាត់ដឹងថាឈ្មោះក្នុងបញ្ជីណាមួយដែលបេក្ខជននោះសម្រេចជ្រើសយក និងបោះបង់។*<br>- **មូលហេតុ ៖** កន្លងមកបេក្ខជនខ្លះមិនដឹងថា ឈ្មោះខ្លួនឯងមាននៅក្នុងបញ្ជីរបស់គណបក្សផ្សេងទៀតនោះទេ ពេលខ្លះក៏កើតឡើងពីកំហុសបច្ចេកទេសផងដែរ ហេតុនេះ ពួកគាត់មិនត្រូវបាត់ឈ្មោះដោយស្វ័យប្រវត្តិនោះទេ គួរតែត្រូវបានជូនដំណឹងឱ្យមានការសម្រេចចិត្ត។ | |
| | **ជំពូកទី ៥**<br>**ការិយាល័យបោះឆ្នោត** | |
| ៥.៦ ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន អុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេស គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម៖ | - **ស្នើសុំបន្ថែម ៖** ត្រូវមានការណែនាំ ឬមានគោលការណ៍ក្នុងការបើក ឬបិទទ្វារ បង្អួច នៃការិយាល័យរាប់សន្លឹកឆ្នោតក្នុងអំឡុងពេលរាប់ព្រមទាំងកំណត់ចម្ងាយក្នុងការឈរមើលឱ្យបានច្បាស់សម្រាប់ពួកគាត់។<br>- **មូលហេតុ ៖** ការផ្ដល់លទ្ធភាពឱ្យប្រជាពលរដ្ឋមើលពីខាងក្រៅឃើញវាជាហេតុផលមួយសម្រាប់តម្លាភាពនៃការរាប់សន្លឹកឆ្នោត។ ការបិទទ្វា រួមទាំងការចាក់សោរ និងបិទបង្អួច នៅការិយាល័យរាប់សន្លឹកឆ្នោត ដោយទីកន្លែងទាំងនោះមិនមានបញ្ហាកើតឡើងលើស្ថានភាពដែលអាចបញ្ជាក់ថាមានអសន្តិសុខ វាបានបង្កើតឱ្យមានការសង្ស័យ និងភាពអស់ចិត្តពីម្ចាស់ឆ្នោត លើភាពត្រឹមត្រូវក្នុងការរាប់សន្លឹកឆ្នោតដោយតម្លាភាព។ | មិនយល់ព្រមតាមសំណើ។<br>យោងតាមជំពូកទី៣ នៃ ច.ប.ត.រ មានតែអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ភ្ញៀវពិសេស និងភ្នាក់ងារគណបក្សនយោបាយប៉ុណ្ណោះ ដែលមានសិទ្ធិសង្កេតការណ៍មើលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។<br>ចាប់ពីមាត្រា ១១៥ រហូតដល់មាត្រា ១២៣ នៃ ច.ប.ត.រ អ្នកដែលមានភារកិច្ចក្នុងកិច្ចដំណើរការរាប់សន្លឹកឆ្នោត មានតែមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្ស អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ តែប៉ុណ្ណោះ។ |
| | **ជំពូកទី ៦**<br>**ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត** | |
| ជំពូកទី៦ | - **ស្នើសុំបន្ថែម ៖** (ប្រការ ឬចំណុចថ្មី) *ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតមកពីសហគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចយកមកជាមួយនូវបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់ និងបញ្ជីឈ្មោះបោះឆ្នោតដែលប្រើសម្រាប់បោះឆ្នោតក្នុងការិយាល័យនោះ នៅថ្ងៃបោះឆ្នោត។* | មិនយល់ព្រមតាមសំណើ។<br>មានតែគណបក្សនយោបាយ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ និងបានចុះបញ្ជីគណបក្សនយោបាយឈរបោះឆ្នោត និងបេក្ខជនឈរឈ្មោះមានសិទ្ធិស្នើសុំ និងប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការរបស់ គ.ជ.ប ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - មូលហេតុ ៖ ការផ្ទៀងផ្ទាត់បញ្ជីឈ្មោះឆ្នោតនៅការិយាល័យបោះឆ្នោត និងធ្វើឱ្យភាគីពាក់ព័ន្ធការបោះឆ្នោតកាន់តែមានទំនុកចិត្តអំពីសុចរិតភាពនៃការប្រើប្រាស់បញ្ជីឈ្មោះបោះឆ្នោត។ម្យ៉ាងទៀត ករណីកត់ឈ្មោះនេះ ក៏បានកើតឡើងក្នុងការបោះឆ្នោតឆ្នាំ២០២២ ដែលមានក្រុមការងារនៃភ្នាក់ងារគណបក្សមួយចំនួនបានប្រើប្រាស់ផងដែរ។ | |
| ៦.៤ ដើម្បីជួយដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានយល់ដឹងច្បាស់អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ... | - **ស្នើសុំបន្ថែម ៖** *<u>ហាមឃាត់ចំពោះភាគីពាក់ព័ន្ធដែលចូលរួមចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត យករូបភាពនៃការចែកប័ណ្ណនេះទៅធ្វើការឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។</u>*<br>- មូលហេតុ ៖ ដើម្បីធានាអព្យាក្រិត្យភាពរបស់ភាគីពាក់ព័ន្ធចំពោះកិច្ចការទាក់ទិន្នការបោះឆ្នោត ដែល គ.ជ.ប បានផ្ទេរភារកិច្ចជូន។ | មិនយល់ព្រមតាមសំណើ។<br>ចំពោះគោលការណ៍ទូទៅ សម្រាប់ការចែកប័ណ្ណព័ត៌មានមានចែងក្នុងសេចក្តីសម្រេចទាក់ទងនឹងបម្រាមផងដែរ។ |
| **ជំពូកទី ៧<br>ការឃោសនាបោះឆ្នោត** | | |
| ជំពូកទី៧ | - ស្នើសុំបន្ថែម ៖ (ចំណុចថ្មី) *<u>គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសរើសតាំងតំណាងរាស្ត្រ ត្រូវដាក់ជូន គ.ជ.ប នូវរបាយការណ៍ស្តីពីប្រភពហិរញ្ញវត្ថុ និងរបាយការណ៍ស្តីពីការចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយខ្លួន តាមមណ្ឌលរាជធានី ខេត្តដែលគណបក្សសាមីបានឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលម្ភៃប្រាំ (២៥) ថ្ងៃ ក្រោយពីប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ។ ក្រោយពីទទួលបានរបាយការណ៍ស្តីពីប្រភពហិរញ្ញវត្ថុ និងរបាយការណ៍ស្តីពីការចំណាយសម្រាប់ការឃោសនាពីគណបក្សនយោបាយ គ.ជ.ប ត្រូវដាក់ផ្សាយរបាយការណ៍នៃគ្រប់គណបក្សនយោបាយជាសាធារណៈក្នុងរយៈពេលសាមសិប (៣០) ថ្ងៃក្រោយពីប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ។</u>* | មិនយល់ព្រមតាមសំណើ។<br>អនុលោមតាមមាត្រា៨៨ និងមាត្រា៩១ នៃ ច.ប.ត.រ គ.ជ.ប អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត តាមការចាំបាច់តែប៉ុណ្ណោះ។ មិនមែនជាលក្ខខណ្ឌដាច់ណាត់ ដែលតម្រូវឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតធ្វើរបាយការណ៍ស្តីពីចំណូល និងចំណាយឡើយ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.គ.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
| --- | --- | --- |
| | - **មូលហេតុ ៖** ការដាក់ជូនរបាយការណ៍អំពីចំណូល និងចំណាយរបស់គណបក្សនយោបាយ និងផ្សាយជាសាធារណៈ នឹងបង្កើតតម្លាភាព និងសុចរិតភាពនៃទាំងគណបក្សនយោបាយ និងដំណើរការបោះឆ្នោត ហើយមាត្រា៨៩ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា គ្រប់គណបក្សបយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនី ដើម្បីកត់ត្រាប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត។ | |
| ជំពូកទី៧ | - **ស្នើសុំបន្ថែម ៖** (ប្រការ ឬចំណុចថ្មី) *មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៧.៩ នឹងត្រូវទទួលទោសតាមបទបញ្ញត្តិនៃ ច.ប.គ.រ។*<br>- **មូលហេតុ ៖** ដើម្បីធានាឱ្យការអនុវត្តប្រការនេះមានប្រសិទ្ធិភាព។ | មិនយល់ព្រមតាមសំណើ។<br>ក្នុងករណីមានពាក្យបណ្តឹងអំពីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិណាម្នាក់ ប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុង ច.ប.គ.រ ជននោះនឹងទទួលទោសតាមបញ្ញត្តិក្នុងជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.គ.រ ហើយ។ |
| ជំពូកទី៧ | - **ស្នើសុំបន្ថែម ៖** (ប្រការ ឬចំណុចថ្មី)*មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៧.១០ នឹងត្រូវទទួលទោសតាមបទបញ្ញត្តិនៃ ច.ប.គ.រ។*<br>- **មូលហេតុ ៖** ដើម្បីធានាឱ្យការអនុវត្តប្រការនេះមានប្រសិទ្ធិភាព។ | មិនយល់ព្រមតាមសំណើ។<br>ក្នុងករណីមានពាក្យបណ្តឹងអំពីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិណាម្នាក់ប្រព្រឹត្តអំពើល្មើសណាមួយ ដូចមានចែងក្នុង ច.ប.គ.រ ជននោះនឹងទទួលទោសតាមបញ្ញត្តិក្នុងជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.គ.រ ហើយ។ |
| ៧.៣.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន។ | - **ស្នើសុំបន្ថែម ៖** *ប្រជាពលរដ្ឋជាម្ចាស់លំឋានមានសិទ្ធិដក ឬបកចេញនូវស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណ ដែលបានលើក ឬបិទដោយមិនបានស្នើសុំ ឬព្រមព្រៀងគ្នាជាមុន។*<br>- **មូលហេតុ ៖** កន្លងមានតំណាងគណបក្សនយោបាយបានលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណ ដោយឯកតោភាគី មិនមានការស្នើសុំ ឬព្រមព្រៀងគ្នាជាមុន ហើយម្ចាស់លំនៅឋានទាំងនោះមិនហ៊ានដក ឬបកចេញ ព្រោះចំណុចនៃប្រការនេះហាក់មិនបានបញ្ជាក់ឱ្យច្បាស់។ | រក្សាទុកដដែល។<br>អនុលោមតាមកថាខណ្ឌទី៣ មាត្រា៦៩ នៃ ច.ប.គ.រ។ ជាគោលការណ៍ ប្រសិនបើគណបក្សនយោបាយបិទសម្ភារឃោសនាបោះឆ្នោត ដោយពុំមានការយល់ព្រមពីម្ចាស់លំនៅឋានទេនោះ ម្ចាស់លំនៅឋានមានសិទ្ធិស្នើ ឬដំណឹងទៅគណបក្សដើម្បីបកសម្ភារឃោសនាបោះឆ្នោតនោះបាន។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| ៧.៨ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។ | - **ស្នើសុំលុប ៖** នូវឃ្លាដែលបានអនុញ្ញាតឱ្យ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីតុលាការ ចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។<br>- **មូលហេតុ ៖** កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីតុលាការ ជាភាគីសំខាន់ចូលរួមរក្សាសន្តិសុខ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ដែលពួកគេត្រូវធ្វើកិច្ចការសម្រាប់ដោះស្រាយឱ្យប្រជាពលរដ្ឋជាចាំបាច់។ ម៉្យាងទៀត នីតិវិធី ត្រូវចែងឱ្យស្របជាមួយច្បាប់របស់ស្ថាប័នដែលបានចែងពីសភាពអព្យាក្រឹតរបស់ស្ថាប័នសាមីនោះ និងក៏ត្រូវមានសមសភាពឱ្យស្របជាមួយការចែងក្នុងចំណុចភាពឥតលម្អៀងនៃអង្គការសង្គមស៊ីវិល។ | រក្សាទុកដដែល។<br>អនុលោមតាមមាត្រា ៨៣ នៃ ច.ប.ត.រ ។ |
| ៧.១៧ អនុលោមតាមប្រការ ៧.២ នៃ ប.ន.ត.រ នេះ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយបានដូចជា៖ | - **ស្នើសុំបន្ថែម ៖** *ហាមធ្វើសកម្មភាពបង្រៀនប្រជាពលរដ្ឋឱ្យគូសសន្លឹកឆ្នោតគ្រប់ប្រភេទ (ទោះជាសន្លឹកឆ្នោតក្រៅផ្លូវការ មិនមែនផលិតដោយ គ.ជ.ប)។*<br>- **មូលហេតុ ៖** ដើម្បីជៀសវាងការភ័ន្តច្រលំរបស់ប្រជាពលរដ្ឋអ្នកបោះឆ្នោត និងអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ប្រជាពលរដ្ឋផងដែរ។ | មិនយល់ព្រមតាមសំណើ។<br>ការបង្រៀនអ្នកបោះឆ្នោតឱ្យគូសសន្លឹកឆ្នោត ជាការចូលរួមអប់រំអ្នកបោះឆ្នោត ដើម្បីកាត់បន្ថយនូវសន្លឹកឆ្នោតខូច ឬសន្លឹកឆ្នោតមិនបានការ។ ប្រជាពលរដ្ឋមានសិទ្ធិចូលរួម ឬមិនចូលរួមក្នុងការបង្រៀនគូសសន្លឹកឆ្នោត។ |
| **ជំពូកទី ៨**<br>**ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត** | | |
| ៨.៥ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចមានចែងក្នុងប្រការ ៥.៥ នៃជំពូកទី៥ នៃ ប.ន.ត.រ នេះ។ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ | - **ស្នើសុំបន្ថែម ៖** គួរឱ្យមានការបើកចំហទ្វាររបងនៃបរិវេណទីតាំងការិយាល័យបោះឆ្នោត និងព្រមទាំងបើកចំហបង្អួច និងទ្វារនៃការិយាល័យរាប់សន្លឹកឆ្នោត បើសិនជាទីនោះមិនមានបញ្ហាអសន្តិសុខទេនោះ។<br>- **មូលហេតុ ៖** ដើម្បីពង្រឹងតម្លាភាពនៃការរាប់សន្លឹកឆ្នោត និងកាត់បន្ថយភាពប្រក្រតីនៃការរាប់សន្លឹកឆ្នោត ព្រោះថាការបិទទ្វាររបង ទ្វារបង្អួច វាមិនបានបង្ហាញនូវតម្លាភាពនោះទេ ផ្ទុយទៅវិញវាបានបង្កើនការសង្ស័យសម្រាប់លទ្ធផលការបោះឆ្នោត។ | មិនយល់ព្រមតាមសំណើ។<br>ការបិទទ្វារ និងបង្អួចអាចធ្វើបានក្នុងករណីមានភ្លៀងធ្លាក់ ឬខ្យល់ដែលអាចនាំឱ្យប៉ះពាល់ដល់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។<br>អ្នកដែលអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងការិយាល័យរាប់សន្លឹកឆ្នោត គឺមានតែជនដែលបានកំណត់ក្នុងចំណុច ៥.៦.៥ នៃ ប.ន.ត.រ ពីព្រោះភ្នាក់ងារគណបក្សគឺជាបុគ្គលដែលមានសិទ្ធិតវ៉ា ឬជំទាស់ទៅ គ.ក.រ អំពីភាពមិនប្រក្រតី |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | | ទាំងឡាយ ដែលកើតមានក្នុងអំឡុងពេលរាប់សន្លឹកឆ្នោត ដែលកត្តានេះគឺជាយន្តការច្បាប់កំណត់អំពីការធានានូវតម្លាភាព និងសុចរិតភាពក្នុងការបោះឆ្នោត ។ |
| ៨.១០.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អាចថតយករូបភាពនៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។ | - ស្នើសុំបន្ថែម ៖ ពង្រឹងនីតីវិធីសម្រាប់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមានលទ្ធភាពថតរូបក្នុងដំណើរការរាប់សន្លឹកឆ្នោត។<br>- មូលហេតុ ៖ ការថតរូបក្នុងដំណើរការរាប់សន្លឹកឆ្នោតបានជម្រុញឱ្យការទុកចិត្តលើលទ្ធផលនៃការរាប់សន្លឹកឆ្នោត និងតម្លាភាពក្នុងការិយាល័យរាប់។ | - គ.ជ.ប សូមថ្លែងអំណរគុណ គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រី គ.ក.រ។<br>- យោងស្មារតីចំណុច ៨.១០.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យថតរូបភាពនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ហើយសកម្មភាពថតរូបភាពនោះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាន គ.ក.រ ស្របតាមការកំណត់ក្នុង ប.ន.ត.រ។ |
| ពង្រឹងនីតិវិធី និងទោសប្បញ្ញត្តិ | - ស្នើសុំបន្ថែម ៖ សម្រាប់មន្ត្រីការិយាល័យបោះឆ្នោតក្នុងការអនុវត្តការសម្រេចចិត្តផ្ទុយពីនីតិវិធីបានចែងសម្រាប់អ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយមិនឱ្យចូលរួមសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។<br>- មូលហេតុ ៖ ការមិនអនុញ្ញាតឱ្យសង្កេតការណ៍ដែលទទួលស្គាល់ដោយ គជប ចូលសង្កេតការណ៍បោះឆ្នោតជាភាពមិនប្រក្រតីមួយ ដែលនាំឱ្យបាត់បង់ភាពទុកចិត្ត និងបង្កើតការសង្ស័យលើតម្លាភាពនៃការរាប់សន្លឹកឆ្នោត។ | អ្នកសង្កេតការណ៍បោះឆ្នោត ដែល គ.ជ.ប បានអនុញ្ញាតជាផ្លូវការ និងមានប័ណ្ណសម្គាល់ខ្លួនត្រឹមត្រូវមានសិទ្ធិចូលរួមសង្កេតការណ៍ ដោយពុំមានការរារាំង និងត្រូវអនុវត្តតួនាទី និងភារកិច្ចស្របតាមការកំណត់នៃច្បាប់ បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌របស់ គ.ជ.ប។ |
| ៨.១០.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួច ហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន គ.ក.រ និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប... | - ស្នើសុំបន្ថែម ៖ ពង្រឹងការអនុវត្តន៍សេចក្ដីណែនាំ អំពីការរាប់សន្លឹកឆ្នោតទប់ស្កាត់មន្ត្រី<br>- មូលហេតុ ៖ ដើម្បីពង្រឹងភាពត្រឹមត្រូវនៃការកត់ត្រា និងកំណត់ហេតុ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>ករណីនេះ មន្ត្រី គ.ក.រ អនុវត្តបានល្អប្រសើរហើយ ប៉ុន្តែ គ.ជ.ប និងយកចិត្តទុកដាក់ពង្រឹងការអនុវត្តឱ្យបានកាន់តែល្អប្រសើរបន្ថែមទៀត។ |
| ៨.១០.១៤ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួច ហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន គ.ក.រ និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោត | - ស្នើសុំបន្ថែម ៖ ការិយាល័យទាមទារឱ្យភ្នាក់ងារគណបក្សចុះហត្ថលេខាលើតារាងកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១០៨) និងកំណត់ហេតុ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រី គ.ក.រ បន្ថែមទៀត។ ដោយឡែកចំពោះ ទ.១១០៣ គឺត្រូវបានគណនា ដោយ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| មិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងបង្គាប់សមាជិកទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។ | នៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ជាមុននៅពេលមិនទាន់បានបញ្ចប់ការរាប់សន្លឹកឆ្នោត។ ពង្រឹងការយកចិត្តទុកដាក់នៃការសរសេរលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវក្នុងក្នុងទម្រង់១១០៨ និងទម្រង់១១០២ និងការបិទផ្សាយទម្រង់១១០២ និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) នៅតាមការិយាល័យគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត។<br>- មូលហេតុ ៖ នៃការរាប់សន្លឹកឆ្នោត និងដើម្បីឱ្យប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធងាយស្រួលក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការរាប់សន្លឹកឆ្នោត។ | ស្វ័យប្រវត្តិក្នុងកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដែលផ្តល់ជូនដោយ គ.ជ.ប បន្ទាប់មកត្រូវបានបោះពុម្ពចេញពីប្រព័ន្ធកំព្យូទ័រ ដើម្បីប្រើប្រាស់ស្របតាមការកំណត់ក្នុង ប.ន.ត.រ។ |
| ៨.១៣.២ ចាត់សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាលស្តែនកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ | - **ស្នើសុំបន្ថែម** ៖ ចែងលំអិតអំពីនីតិវិធីអំពីការនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយមន្ត្រីគករ មក គ.ជ.ប និងផ្សព្វផ្សាយកំណត់ហេតុនេះរបស់ គ.ជ.ប។ ទ.១១០២ គួរត្រូវបញ្ជូនជាបន្ទាន់មក គ.ជ.ប ដោយមន្ត្រីគករ នៅបន្ទាប់ពីការរាប់សន្លឹកឆ្នោតតាមការិយាល័យនីមួយៗចប់សព្វគ្រប់ តាមមធ្យោបាយអេឡិត្រូនិច (Online) ហើយ គ.ជ.ប ត្រូវបង្ហោះនៅក្នុងវេបសាយ ឬ/និងប្រព័ន្ធបណ្តាញសង្គមរបស់ខ្លួន។<br>- **មូលហេតុ** ៖ កំណត់ហេតុលទ្ធផលរាប់សន្លឹកឆ្នោត ត្រូវបានបិទផ្សាយជាសាធារណៈ ទាំងនៅការិយាល័យ និងនៅវេបសាយ ឬ/និងប្រព័ន្ធបណ្តាញសង្គមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យប្រជាពលរដ្ឋងាយក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការរាប់សន្លឹកឆ្នោត។ | មិនយល់ព្រមតាមសំណើ។<br>ក្នុងដំណើរការធ្វើទំនើបកម្មការគ្រប់គ្រងលទ្ធផល នៃការបោះឆ្នោត គ.ជ.ប បានផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសជូន គឃ.សប និងបានកំណត់ឱ្យ គឃ.សប គឺជាប្រតិបត្តិករដំបូងក្នុងការបញ្ចូល និងបញ្ជូនទិន្នន័យ ទ.១១០២ មក គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងផ្សព្វផ្សាយជាព័ត៌មានលទ្ធផលបឋមនៃការបោះឆ្នោត។ |
| ៨.១៣.៣ បញ្ចូលទិន្នន័យ និងតួលេខលទ្ធផលពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងចំណុច ៨.១៣.២ | - **ស្នើសុំបន្ថែម** ៖ ចែងលំអិតអំពីនីតិវិធីអំពីការនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយមន្ត្រីគករ មក គ.ជ.ប និងផ្សព្វផ្សាយកំណត់ហេតុនេះរបស់ គ.ជ.ប។ ទ.១១០២ គួរត្រូវបញ្ជូនជាបន្ទាន់មក គ.ជ.ប ដោយមន្ត្រីគករ នៅបន្ទាប់ពីការរាប់សន្លឹកឆ្នោតតាមការិយាល័យនីមួយៗ | មិនយល់ព្រមតាមសំណើ។<br>ក្នុងដំណើរការធ្វើទំនើបកម្មការគ្រប់គ្រងលទ្ធផល នៃការបោះឆ្នោត គ.ជ.ប បានផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសជូន គឃ.សប និងបានកំណត់ឱ្យ គឃ.សប គឺជាប្រតិបត្តិករ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|---|
| | ខាងលើនេះ បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតរួចបញ្ជូនមក គ.ជ.ប តាមអ៊ីនធឺណិត ដើម្បីផ្សាយជាព័ត៌មានអំពីលទ្ធផលបឋមនៃការបោះឆ្នោត។ | ចប់សព្វគ្រប់ តាមមធ្យោបាយអេឡិត្រូនិច (Online) ហើយ គ.ជ.ប ត្រូវបង្ហោះនៅក្នុងវេបសាយ ឬ/និងប្រព័ន្ធបណ្ដាញសង្គមរបស់ខ្លួន។<br>- **មូលហេតុ ៖** កំណត់ហេតុលទ្ធផលរាប់សន្លឹកឆ្នោត ត្រូវបានបិទផ្សាយជាសាធារណៈ ទាំងនៅការិយាល័យ និងនៅវេបសាយ ឬ/និងប្រព័ន្ធបណ្ដាញសង្គមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យប្រជាពលរដ្ឋងាយក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការរាប់សន្លឹកឆ្នោត។ | ដំបូងក្នុងការបញ្ចូល និងបញ្ជូនទិន្នន័យ ទ.១១០២ មក គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងផ្សព្វផ្សាយជាព័ត៌មានលទ្ធផលបឋមនៃការបោះឆ្នោត។ |
| ៨.១៣.៤ | បន្ទាប់មកសមាជិក គយ.សប ទទួលបន្ទុកលើការងាររដ្ឋបាលត្រូវបោះពុម្ពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានក្នុងចំណុច ៨.១៣.២ ខាងលើនេះ តាមចំនួនគ្រប់គ្រាន់ និងត្រូវបោះត្រា គយ.សប សម្រាប់ផ្ដល់ជូនភ្នាក់ងារគណបក្សនយោបាយ តាមការស្នើសុំ។ | - **ស្នើសុំបន្ថែម ៖** ការបែងចែក ទ.១១០២ ត្រូវផ្ដល់ជូនដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយនៅការិយាល័យ និងនៅ គយ.សប។ ប្រការនេះ ត្រូវចែងពីទោសទណ្ឌឱ្យបានតឹងរឹងផងដែរ។<br>- **មូលហេតុ ៖** កន្លងមក សំអាងលើនីតិវិធីដែលបានចែងនេះ គយ.សប នៅកន្លែងខ្លះមិនបានផ្ដល់ទម្រង់នេះជូនដល់អ្នកសង្កេតការណ៍នោះទេ។ ការចែងច្បាស់លាស់ពីទោសទណ្ឌរបស់មន្ត្រី ជាការបង្កើនប្រសិទ្ធិភាពការអនុវត្តគោលការណ៍របស់មន្ត្រីការិយាល័យបោះ និងរាប់សន្លឹកឆ្នោតផងដែរ។ | មិនយល់ព្រមតាមសំណើ។<br>ក្នុងការអនុវត្តកន្លងមក គយ.សប ស្ទើរតែទាំងអស់អនុវត្តបានត្រឹមត្រូវស្របតាមការកំណត់ក្នុងបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតហើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ.ជ.ប នឹងខិតខំតាមដាន និងពង្រឹងការអនុវត្តរបស់មន្ត្រី គយ.សប ឱ្យកាន់តែល្អប្រសើរថែមទៀត ហើយក្នុងករណីមានពាក្យបណ្ដឹង គ.ជ.ប នឹងពិនិត្យដោះស្រាយតាមករណីជាក់ស្ដែង។ |
| ៨.១៧.១ | ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្ដឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖ | - **ស្នើសុំបន្ថែម ៖** ក្នុងសេចក្ដីព្រាងបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ មានព័ត៌មានពីប្រភេទគឺ៖ ព័ត៌មានដែលចាំបាច់ (ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង, កម្មវត្ថុនៃបណ្ដឹង, ប្រភេទនៃអំពើល្មើស និងពេលវេលា ទីកន្លែងប្រព្រឹត្តល្មើស ឬភាពមិនប្រក្រតី)។ យើងអាចកំណត់ថា ជាព័ត៌មានមិនចាំបាច់ដែលត្រូវតែមាន គឺជាព័ត៌មានដែលភ្ជាប់ដោយពាក្យបើអាចធ្វើបាន ឬបើមាន ក្នុងប្រភេទព័ត៌មាននីមួយៗ ឬថាព័ត៌មានទាំងនេះអ្នកប្ដឹងមានក្នុងដៃក៏បាន មិនមានក៏បាន)។<br>- **មូលហេតុ ៖** រយៈពេលនៃការដាក់ពាក្យបណ្ដឹងខ្លីដែលភាគីដើមបណ្ដឹងពិបាកក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបាន | មិនយល់ព្រមតាមសំណើ។<br>ខ្លឹមសារចំណុចនេះមានន័យគ្រប់គ្រាន់ សម្រាប់អនុវត្តហើយ ព្រោះព័ត៌មានមួយចំនួនអ្នកប្ដឹងមិនចាំបាច់ ផ្ដល់ជូនក៏បាន ឬអាចផ្ដល់ជូនក៏បាន ប្រសិនបើគាត់មានតែប៉ុណ្ណោះ។ រីឯនីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹង គឺ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តែងតែយកចិត្តទុកដាក់ពិនិត្យ និងស៊ើបអង្កេតស្រាវជ្រាវ ដើម្បីប្រមូលព័ត៌មានបន្ថែម មុននឹងធ្វើការចេញសេចក្ដីសម្រេច។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
| --- | --- | --- |
| | គ្រប់គ្រាន់ ឬព័ត៌មានផ្សេងៗទៀតដែលបទបញ្ជា និងនីតិវិធី មិនបានចាត់ថ្នាក់ជាព័ត៌មានចាំបាច់ត្រូវតែមាន។ លើសពីនេះទៅទៀត គឃ/សប ឬ គធ/ខប ឬ គ.ជ.ប ត្រូវបើកការស៊ើបអង្កេត ស្រាវជ្រាវបន្ថែមទៅលើអង្គហេតុ ដើម្បីស្វែងរកការពិតនៅពេលមានបណ្ដឹងណាមួយ។ | |
| ៨.២០.១.៤ សម្រេចកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតនៅការិយា-ល័យបោះឆ្នោតនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន... | - **ស្នើសុំបន្ថែម ៖** នីតិវិធីត្រូវកំណត់ឱ្យច្បាស់ មិនគួរប្រើប្រាស់ទឹកលុបលើទម្រង់ទ.១១០២ នេះទេ។ គ.ជ.ប ត្រូវធ្វើការណែនាំដល់មន្ត្រីថ្នាក់ក្រោមពីនីតិវិធីក្នុងការបំពេញឱ្យបានត្រឹមត្រូវតាមសេចក្ដីណែនាំ។<br>- **មូលហេតុ ៖** ការប្រើប្រាស់ទឹកលុបដោយមិនគូរឆូត និងសរសេរតួលេខថ្មីរួមទាំងការបញ្ជាក់មូលហេតុវានាំឱ្យមានការសង្ស័យ និងតវ៉ាពីភាពត្រឹមត្រូវនៃការប្រកាសលទ្ធផល។ | រក្សាទុកដដែល។<br>ខ្លឹមសារចំណុច ៨.២០.១.៤ នេះ មានន័យគ្រប់គ្រាន់សម្រាប់អនុវត្តហើយ។ គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រី គឃ.សប បន្ថែមទៀត។ |
| ៨.២០.៦ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ត្រូវដាក់បង្ហាញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ។ | - **ស្នើសុំបន្ថែម ៖** ការិយាល័យទាមទារឱ្យភ្នាក់ងារគណបក្សចុះហត្ថលេខាលើតារាងកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ជាមុននៅពេលមិនទាន់បានបញ្ចប់ការរាប់សន្លឹកឆ្នោត។ ពង្រឹងការយកចិត្តទុកដាក់នៃការសរសេរលទ្ធផល នៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវក្នុងក្នុចឆងទម្រង់១១០៨ និងទម្រង់១១០២ និងការបិទផ្សាយទម្រង់១១០២ និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) នៅតាមការិយាល័យគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត។<br>- **មូលហេតុ ៖** នៃការរាប់សន្លឹកឆ្នោត និងដើម្បីឱ្យប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធងាយស្រួលក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការរាប់សន្លឹកឆ្នោត។ | រក្សាទុកដដែល។<br>ទ.១១០៣ ត្រូវបានគណនាដោយស្វ័យប្រវត្តិតាមកម្មវិធីដែល គ.ជ.ប បានផ្ដល់ជូនរួចត្រូវបោះពុម្ពតាមចំនួនចាំបាច់គ្រប់គ្រាន់ សម្រាប់ប្រើប្រាស់តាមការកំណត់ក្នុង ប.ន.ត.រ។ |
| ៨.២១.១ ប្រសិនបើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់មានភស្តុតាងបញ្ជាក់ថា មានអំពើរំលោភ ឬមាន | - **ស្នើសុំបន្ថែម ៖** បទបញ្ជា និងនីតិវិធីគប្បីចែងឱ្យបានច្បាស់អំពីនិយមន័យនៃភាពមិនប្រក្រតីធ្ងន់ធ្ងរធ្វើឱ្យប៉ះពាល់ | រក្សាទុកដដែល។ |

| | ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|---|
| | ភាពមិនប្រក្រតីធ្ងន់ធ្ងរធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គយ.សប អាចបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។ ករណីនេះ នៅពេលកំពុងអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.២០.១ ខាងលើនេះ ប្រធាន គយ.សប ត្រូវៈ | ដល់លទ្ធផលនៃការបោះឆ្នោត។ តើអ្វីខ្លះដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីធ្ងន់ធ្ងរ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត? ឧ. តើវត្តមានសន្លឹកឆ្នោតមិនបានការច្រើនក្នុងការិយាល័យមួយ ឬច្រើនក្នុងឃុំសង្កាត់ ជាភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែរឬទេ? គ.ជ.ប គប្បីមានការបញ្ជាក់ការកំណត់ ឬយ៉ាងហោចណាស់មានជាសេចក្តីណែនាំក្នុងសៀវភៅណែនាំស្តីអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងបោះឆ្នោត ឱ្យបានច្បាស់បន្ថែមទៀតអំពីពាក្យថា <u>*ភាពមិនប្រក្រតីធ្ងន់ធរធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត*</u>។<br>- **មូលហេតុ ៖** ព្រោះដើម្បីជៀសវាងការបកស្រាយទូលំទូលាយ និងការអនុវត្តន៍ឆន្ទានុសិទ្ធិទូលាយជ្រុល។ | ការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយត្រូវបានកំណត់ក្នុងចំណុច ៨.១៨.២ នៃ ប.ន.ត.រ នេះរួចហើយ។ |
| ៨.២៧.៣ | ភ្នាក់ងារគណបក្សនយោបាយ ឬតំណាងដែលមានបំណងប្តឹង ដូចមានក្នុងប្រការ ៨.២៧ ខាងលើនេះ ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោមៈ | - **ស្នើសុំបន្ថែម ៖** ក្នុងសេចក្តីព្រាងបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ មានព័ត៌មានពីប្រភេទគឺៈ ព័ត៌មានដែលចាំបាច់ (ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង, កម្មវត្ថុនៃបណ្តឹង, ប្រភេទនៃអំពើល្មើស និងពេលវេលា ទីកន្លែងប្រព្រឹត្តល្មើស ឬភាពមិនប្រក្រតី)។ យើងអាចកំណត់ថា ជាព័ត៌មានមិនចាំបាច់ដែលត្រូវតែមាន គឺជាព័ត៌មានដែលភ្ជាប់ដោយពាក្យបើអាចធ្វើបាន ឬបើមាន ក្នុងប្រភេទព័ត៌មាននីមួយៗ ឬថាព័ត៌មានទាំងនេះអ្នកប្តឹងមានក្នុងដៃក៏បាន មិនមានក៏បាន)។<br>- **មូលហេតុ ៖** រយៈពេលនៃការដាក់ពាក្យបណ្តឹងខ្លីដែលភាគីដើមបណ្តឹងពិបាកក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបានគ្រប់គ្រាន់ ឬព័ត៌មានផ្សេងៗទៀតដែលបទបញ្ជា និងនីតិវិធីមិនបានចាត់ថ្នាក់ជាព័ត៌មានចាំបាច់ត្រូវតែមាន។ លើសពីនេះទៅទៀត គយ/សប ឬ គធ/ខប ឬ គ.ជ.ប ត្រូវបើកការស៊ើបអង្កេត ស្រាវជ្រាវបន្ថែមទៅលើអង្គហេតុ ដើម្បីស្វែងរកការពិតនៅពេលមានបណ្តឹងណាមួយ។ | មិនយល់ព្រមតាមសំណើ។<br>ខ្លឹមសារចំណុចនេះមានន័យគ្រប់គ្រាន់ សម្រាប់អនុវត្តហើយ ព្រោះព័ត៌មានមួយចំនួនអ្នកប្តឹងមិនចាំបាច់ ផ្តល់ជូនក៏បាន ឬអាចផ្តល់ជូនក៏បាន ប្រសិនបើគាត់មានតែប៉ុណ្ណោះ។ រីឯនីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង គឺ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តែងតែយកចិត្តទុកដាក់ពិនិត្យ និងស៊ើបអង្កេតស្រាវជ្រាវ ដើម្បីប្រមូលព័ត៌មានបន្ថែម មុននឹងធ្វើការចេញសេចក្តីសម្រេច។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
| --- | --- | --- |
| **ជំពូកទី ១០**<br>**នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ** | | |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម ៖** (គួរមានចែងលម្អិត) បើមានពាក្យបណ្តឹង គឃ.សប ឬគធ.ខប នៅក្នុងសៀវភៅណែនាំព័ណ៌បៃតង របស់ គ.ជ.ប ស្តីអំពីនីតីវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងបោះឆ្នោត គប្បីពន្យល់ និងណែនាំឱ្យបានច្បាស់អំពីព័ត៌មានចាំបាច់ និងព័ត៌មានមិនចាំបាច់។<br>- **មូលហេតុ ៖** វិធានការនេះ គឺដើម្បីបង្រួមការបកស្រាយ ឬការទាមទារនូវព័ត៌មានណាដែលច្បាប់មិនបានតម្រូវជាដាច់ខាតថា ព័ត៌មាននោះត្រូវតែមាន ករណីគ្មានព័ត៌មានទាំងនោះនឹងត្រូវចារបដិសេធ។ វិធានការនេះក៏ជួយគាំទ្រនូការយល់ច្រឡំ ឬការយល់ដឹងស្រពេចស្រពិលរបស់មន្ត្រីទទួលបន្ទុកទទួលពាក្យបណ្តឹងដែរ អំពីព័ត៌មានត្រូវចាំបាច់ត្រូវតែមាន និងព័ត៌មានមិនដាច់ខាត។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>ចំពោះខ្លឹមសារពាក់ព័ន្ធនឹងព័ត៌មានចាំបាច់ ដែលត្រូវបញ្ជាក់ក្នុងពាក្យបណ្តឹង (ទ.១២០២) គឺមានន័យគ្រប់គ្រាន់សម្រាប់អនុវត្តហើយ។ ចំពោះព័ត៌មានដែលមានបញ្ជាក់ថា "ប្រសិនបើមាន" នោះ គឺអ្នកប្តឹងមិនបាច់បញ្ជាក់ក៏បានប្រសិនបើគាត់មិនមាន។ |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម ៖** (គួរមានចែងលម្អិត) គ.ជ.ប ត្រូវមានសៀវភៅណែនាំលម្អិត ស្តីពីការទទួលពាក្យបណ្តឹង និងការសង្កេតសម្រាប់គណៈកម្មការទទួលពាក្យបណ្តឹង និងស៊ើបអង្កេត ។<br>- **មូលហេតុ ៖** ដើម្បីឱ្យគណៈកម្មការនេះអនុវត្តការងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>ចំពោះនីតិវិធីទទួលពាក្យបណ្តឹង គឺមានចែងច្បាស់ហើយ ទាំងក្នុងបទបញ្ជា និងនីតិវិធី និងសៀវភៅណែនាំរបស់ គ.ជ.ប ហើយកន្លងមកមន្ត្រីទទួលបន្ទុកកិច្ចការនេះបានអនុវត្តល្អប្រសើរហើយ។ រីឯបច្ចេកទេសនៃការស៊ើបអង្កេតស្រាវជ្រាវ គឺរៀងរាល់ការបោះឆ្នោតនីមួយៗ គ.ជ.ប តែងតែបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អំពីនីតិវិធី និងបច្ចេកទេសស៊ើបអង្កេតស្រាវជ្រាវទៅតាមប្រភេទនៃពាក្យបណ្តឹង ដែលកើតមានឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត។ |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម ៖** (គួរមានចែងលម្អិត) ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប គណៈកម្មការទទួលពាក្យបណ្តឹង និងអង្កេតបណ្តឹងបោះឆ្នោត គួរត្រូវបានបង្កើតឡើង ដែលមានសមាសភាពចូលគ្នាមកពីសមាជិក គ.ជ.ប និងមន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ។ | អនុលោមតាម ច.គ.ជ.ប អគ្គលេខាធិការដ្ឋាន គឺជាជំនួយការរបស់ គ.ជ.ប ក្នុងការរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតតាមការកំណត់នៃច្បាប់។ ចំពោះការងារទទួលពាក្យបណ្តឹង និងការស៊ើបអង្កេតស្រាវជ្រាវ ត្រូវ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | គណៈកម្មការនេះ មានភារកិច្ចទទួលពាក្យបណ្ដឹងជំនួស ឱ្យឬជួយការងាររបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប និងតួនាទី ក្នុងកិច្ចការស៊ើបអង្កេតបណ្ដឹងលើបណ្ដឹងដែល គ.ជ.ប បានទទួល។<br>- មូលហេតុ ៖ ដើម្បីធានាថា រាល់ពាក្យបណ្ដឹងដែលត្រូវបានពិនិត្យ និងទទួលដោយគណៈកម្មការ ដែលមកពីសមាសភាពចម្រុះ ហើយពាក្យបណ្ដឹងនោះទៀតសោតត្រូវបានស៊ើបអង្កេតស្វែងរកអង្គហេតុឱ្យបានច្បាស់លាស់ ដើម្បីផ្ដល់នូវភាពយុត្តិធម៌ និងតម្លាភាពដល់ភាគីវិវាទពាក់ព័ន្ធនឹងបណ្ដឹង។ | បានអនុវត្តដោយមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលមានបទពិសោធន៍ជំនាញច្បាស់លាស់ ប្រកបដោយវិជ្ជាជីវៈខ្ពស់ និងត្រូវនៅក្រោមការតាមដាន និងត្រួតពិនិត្យដោយសមាសភាព គ.ជ.ប ទាំង ៩រូប។ ចំពោះការសម្រេចសេចក្ដីលើករណីពាក្យបណ្ដឹង/សំណុំរឿងនីមួយៗ គឺជាឆន្ទានុសិទ្ធិរបស់សមាសភាព គ.ជ.ប ទាំង ៩ រូប ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។ |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម៖** (បញ្ចូលប្រការណាមួយក្នុងផ្នែកទី២) នីតិវិធីគួរចង្អុលបង្ហាញបន្ថែម និងឱ្យមានការបិទផ្សាយជាសធារណៈ នៅទីស្ដីការ គឃ.សប គធ.ខប និង គ.ជ.ប និងនៅលើគេហទំព័ររបស់ គ.ជ.ប ជាដើម ពីលិខិតជូនដំណឹងអំពីការបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការលើបណ្ដឹងបោះឆ្នោត។<br>- **មូលហេតុ** ៖ ការបិទផ្សាយជាសាធារណៈ គឺដើម្បីជូនដំណឹងដល់សាធារណជន អ្នកសង្កេតការណ៍បោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬភាគីពាក់ព័ន្ធនឹងបណ្ដឹងអាចទទួលបានព័ត៌មានអំពីការបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ លើបណ្ដឹងបោះឆ្នោតមួយ និងធានាបាននូវសិទ្ធិទទួលបានព័ត៌មាននៃការប្រព្រឹត្តទៅនៃការដោះស្រាយបណ្ដឹងបោះឆ្នោត និងការចូលរួមរបស់ពួកគេ។ | ការស្នើសុំនេះ គឺជាយន្តការដែល គ.ជ.ប បាន និងកំពុងបន្តអនុវត្តនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត។ ចំពោះការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត គឺ គ.ជ.ប មិនត្រឹមតែផ្សព្វផ្សាយនៅលើគេហទំព័រតែមួយប៉ុណ្ណោះទេ គឺថែមទាំងបានផ្សព្វផ្សាយតាមទំព័រ Facebook កម្មវិធីទូរសព្ទដៃទំនើប App NEC KH ព្រមទាំងសារព័ត៌មានអេឡិចត្រូនិកមួយចំនួនផងដែរ។ |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម** ៖ (បន្ថែមប្រការសម្រាប់នីតិវិធីសម្រេចក្ដី) គប្បីបង្កើតនីតិវិធីនៃការសម្រេចតាមដំណាក់កាល ដូចជាជាការព្រមាន ការស្ដីបន្ទោស ការទាមទារឱ្យមានការប្រកាសទទួលកំហុសជាសាធារណៈ និងការធានាអះអាងសន្យាជា | ជាគោលការណ៍ ការពិន័យចំពោះជនដែលបានប្រព្រឹត្តបំពាននឹងច្បាប់បោះឆ្នោត ត្រូវអនុវត្តដោយអនុលោមតាមជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | លាយលក្ខណអក្សរ ចុះផ្សាយជាសាធារណៈ (វិធានការកាតលឿង) គប្បីធ្វើនៅក្នុងដំណាក់កាលដំបូងអាស្រ័យលើស្ថានទម្ងន់ចរិតលក្ខណៈ ឬប្រភេទនៃបទល្មើស និងចរិត ឬបុគ្គលិកលក្ខណៈនៃជនដែលត្រូវបានរកឃើញថា បានប្រព្រឹត្តល្មើស មូលហេតុសមស្របណាមួយ ដែលមានចរិតលក្ខណៈស្រាល ការធ្វេសប្រហែស ឬការមិនយល់ដឹងអំពីច្បាប់។ កម្រិតបន្ទាប់ បើអំពើល្មើសអំណាច និងក្រមសីលធម៌ មានចរិតលក្ខណៈធ្ងន់ធ្ងរកម្រិតមធ្យម គួរមានវិធានការពិន័យកាតក្រហមជាមួយវិធានការវិន័យ ដែលជននោះប្រព្រឹត្តល្មើសច្បាប់ ឬបន្តបំពានល្មើសក្រមសីលធម៌លើសមួយដង។<br>- **មូលហេតុ ៖** វិធានការនេះ អាចជួយបន្ថយបញ្ហាបដិវាទ (Controversy) អំពីការដាក់ទោស សិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពក្នុងជីវភាពនយោបាយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ | |
| ជំពូកទី១០ | - **ស្នើសុំបន្ថែម ៖** ( បន្ថែមប្រការណាមួយនៃផ្នែកទី១ ឬទី២) គួរជាប្រព័ន្ធទិន្នន័យផ្ទុកទិន្នន័យមួយ ដែលអាចដាក់ក្នុងគេហទំព័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបង្កភាពងាយស្រួលដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត អ្នកសិក្សាស្រាវជ្រាវ ភាគីពាក់ព័ន្ធ និងសាធារណជនអាចចូលមើល និងទាញយកមកធ្វើជាប្រភពសម្រាប់ការសិក្សាស្រាវជ្រាវ និងស្វែងយល់។<br>- **មូលហេតុ ៖** ការបង្កលក្ខណៈងាយស្រួលបែបនេះ គឺដើម្បីបង្កើនតម្លាភាពនៃការគ្រប់គ្រង និងភាពត្រឹមត្រូវលើដំណើរការដោះស្រាយវិវាទបោះឆ្នោត។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពិចារណាអំពីករណីនេះ។ |
| ១០.២.១ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។ អ្នកប្តឹងដំបូងអាចថតចម្លងពាក្យ | - **ស្នើសុំបន្ថែម ៖** មន្ត្រីទទួលបន្ទុកទទួលពាក្យបណ្តឹង មានភារកិច្ចជួយសរសេរពាក្យបណ្តឹងបើមានការស្នើសុំពីអ្នកប្តឹង។ | គ.ជ.ប សូមថ្លែងអំណរគុណ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|---|
| | បណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជូនខ្លួនបាន។ | - មូលហេតុ ៖ គឺដើម្បីជួយសម្រួលអ្នកមកប្តឹង ដែលមានអនក្ខរកម្មភាព ឬមិនសូវចេះសរសេរ ហើយម្យ៉ាងទៀតនីតិវិធីដាក់ពាក្យបណ្តឹងបានលុបការទទួលពាក្យបណ្តឹងដោយផ្ទាល់មាត់ហើយ។ | ជាគោលការណ៍ មិនចែងចងជាភារកិច្ចឱ្យមន្ត្រីទទួលបន្ទុក ទទួលពាក្យបណ្តឹងត្រូវតែអនុវត្តនោះទេ ព្រោះក្នុងពេលប្រតិបត្តិការងារងារ មន្ត្រីបោះឆ្នោតទាំងនោះត្រូវបំពេញភារកិច្ចច្រើនក្នុងពេលតែមួយ ហើយកិច្ចការទាំងនេះសុទ្ធតែបានកំណត់អំពីពេលវេលាជាក់លាក់ សម្រាប់អនុវត្តថែមទៀតផង។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងមន្ត្រីទទួល ពាក្យបណ្តឹងនៅគ្រប់យន្តការទាំងអស់តែងតែជួយសម្របសម្រួលដល់អ្នកប្តឹង ដែលមិនអាចសរសេរពាក្យបណ្តឹងដោយខ្លួនឯងបាន តាមការស្នើសុំរបស់សាមីអ្នកប្តឹង (ដោយណែនាំឱ្យអ្នកប្តឹងរកអ្នកផ្សេង ដែលមិនមែនជាមន្ត្រីបោះឆ្នោតសរសេរឱ្យ)។ |
| ១០.២.៦ | ក្រុមត្រួតពិនិត្យត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង។ | - **ស្នើសុំបន្ថែម ៖** ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្តឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងដែលបានប្តឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្តឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្តឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា លើបណ្តឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្តឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្តោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - មូលហេតុ ៖ ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | |
| ១០.២.៧ បន្ទាប់ពីក្រុមត្រួតពិនិត្យស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះមិនបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ប.ន.ត.រ គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន អ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ | - **ស្នើសុំបន្ថែម** ៖ ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្ដឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្ដឹងដែលបានប្ដឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្ដឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្ដឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា លើបណ្ដឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្ដឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្ដោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។<br>- **មូលហេតុ** ៖ ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |
| ១០.២.៨ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់បានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ប.ន.ត.រ គឃ.សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គឃ.សប។ | - **ស្នើសុំបន្ថែម** ៖ ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្ដឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្ដឹងដែលបានប្ដឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័ន | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | ដោះស្រាយបណ្ដឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្ដឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា លើបណ្ដឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្ដឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្ដោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។<br>- **មូលហេតុ ៖** ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | |
| ១០.២.១៩ ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖ | - **ស្នើសុំបន្ថែម ៖** ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្ដឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្ដឹងដែលបានប្ដឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្ដឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្ដឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា លើបណ្ដឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្ដឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្ដោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.គ.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - មូលហេតុ ៖ ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | |
| ១០.២.២០ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្ដុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្ដឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្ដឹង ឬតំណាង។ | - **ស្នើសុំបន្ថែម** ៖ ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្ដឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្ដឹងដែលបានប្ដឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្ដឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្ដឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា លើបណ្ដឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្ដឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្ដោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។<br>- មូលហេតុ ៖ ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្ដឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |
| ១០.២.២១ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះមិនបានបំពានលើបទប្បញ្ញត្តិ | - **ស្នើសុំបន្ថែម** ៖ ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្ដឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យកាន់តែល្អប្រសើរថែមទៀត។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
| --- | --- | --- |
| នៃ ច.ប.ត.រ និង ប.ន.ត.រ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ | បណ្តឹងដែលបានប្តឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្តឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្តឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាលើបណ្តឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្តឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្តោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។<br>- **មូលហេតុ ៖** ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្តឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | |
| ១០.២.៣២ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថាៈ | - **ស្នើសុំបន្ថែម ៖** ក្រុមពិនិត្យ និងស្រាវជ្រាវនៃ គឃ.សប និង គធ.ខប ឬគណៈកម្មការទទួលពាក្យបណ្តឹង និងស៊ើបអង្កេតនៃ គ.ជ.ប ត្រូវធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងដែលបានប្តឹងមក ក្នុងរយៈពេលសមស្របមួយបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។ ខ្លឹមសារនៃប្រការពាក់ព័ន្ធខាងលើ បានចង្អុលបង្ហាញ និងតម្រូវឱ្យស្ថាប័នដោះស្រាយបណ្តឹងនៃ គ.ជ.ប បើកការស៊ើបអង្កេតលើបណ្តឹងបោះឆ្នោតជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាលើបណ្តឹងដែលខ្លួនបានទទួល។ ស្នើសុំ គ.ជ.ប ពង្រឹងការ | គ.ជ.ប សូមថ្លែងអំណរគុណ។<br>គ.ជ.ប នឹងពង្រឹងការអនុវត្តរបស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យកាន់តែល្អប្រសើរថែមទៀត។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | អនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា បណ្តឹងដែលបានទទួលដោយស្ថាប័នទាំងនោះ។ ជាចំណាត់ការបន្ថែម គ.ជ.ប ឬស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងនៃ គ.ជ.ប អាចមានចំណាត់ការបណ្តោះអាសន្នទាន់ពេលវេលា ចំពោះករណីមិនប្រក្រតីនោះ។<br>- មូលហេតុ ៖ ការស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តបញ្ញត្តិនៃប្រការពាក់ព័ន្ធខាងលើ វាជាការអនុវត្តមួយដែលមានប្រសិទ្ធិភាព ដើម្បីធានាថា បណ្តឹងដែលបានទទួលក្នុងដំណាក់កាលនីមួយៗ ត្រូវបានយកចិត្តទុក និងធានានូវតម្លាភាព និងយុត្តិធម៌ជូនភាគីពាក់ព័ន្ធក្នុងរឿង។ | |
| ១០.៤ គយ.សប គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គយ.សប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច គធ.ខប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬ/និងបើកសវនាការ និង គ.ជ.ប ប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។ | - ស្នើសុំបន្ថែម ៖ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្តឹងតវ៉ា និងជំទាស់នៃបណ្តឹងបោះឆ្នោត ដែលធ្វើឡើងដោយ គយ.សប គធ.ខប គ.ជ.ប ត្រូវមានប្រការ ឬអនុប្រការណាមួយនៃប្រការទាំងនេះ ត្រូវចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្តឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធារណៈ។ ដូចគ្នាដែរ សវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោល ឬនីតិវិធីដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលប្រព្រឹត្តទៅដោយ គ.ជ.ប និងស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងរបស់ខ្លួន គប្បីធ្វើឡើងជា "សាធារណៈ" ផងដែរ។<br>- មូលហេតុ ៖ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្តឹងតវ៉ា និងជំទាស់នៃបណ្តឹងបោះឆ្នោត ដែលធ្វើឡើងដោយ គយ.សប គធ.ខប | រក្សាទុកដដែល។<br>ប្រការនេះចែងកំណត់អំពីសមត្ថកិច្ច សិទ្ធិអំណាច និងភារកិច្ចរបស់ គយ.សប គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ លើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប៉ុណ្ណោះ។ រីឯប្រភេទនៃសវនាការដោះស្រាយពាក្យបណ្តឹង គឺមានចែងក្នុងចំណុច ១០.១១.១ នៃ ប.ន.ត.រ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.គ.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | និង គ.ជ.ប មិនមានប្រកាស ឬអនុប្រកាសណាមួយនៃប្រកាសទាំងនេះចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្តឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធរណៈឡើយ។ ការបើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬបើកសវនាការលើបណ្តឹងបោះឆ្នោត គប្បីធ្វើឡើងជាសាធរណៈ និងបើកចំហក្នុងន័យដើម្បីធានាឱ្យមានការចូលរួមសង្កេតឃ្លាំមើលពីអ្នកសង្កេតការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬសាធារណជន និងជាពិសេសភាគីពាក់ព័ន្ធនឹងបណ្តឹង អាចមានសិទ្ធិ និងលទ្ធភាពចូលរួមដោយទូលំទូលាយ ពេញលេញ និងព្រមទាំងធានានូវតម្លាភាព និងភាពត្រឹមត្រូវនៃការដោះស្រាយបណ្តឹងបោះឆ្នោតមួយ។ | |
| ១០.៥ ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប។ | - ស្នើសុំបន្ថែម ៖ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្តឹងតវ៉ា និងជំទាស់នៃបណ្តឹងបោះឆ្នោត ដែលធ្វើឡើងដោយ គឃ.សប គធ.ខប គ.ជ.ប ត្រូវមានប្រកាស ឬអនុប្រកាសណាមួយនៃប្រកាសទាំងនេះ ត្រូវចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្តឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធារណៈ។ ដូចគ្នាដែរ សវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោល ឬនីតិវិធីដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលប្រព្រឹត្តទៅដោយ គ.ជ.ប និងស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងរបស់ខ្លួន គប្បីធ្វើឡើងជា "សាធារណៈ" ផងដែរ។ | រក្សាទុកដដែល។<br>ប្រកាសនេះចែងកំណត់អំពីសមាសភាពក្រុមប្រឹក្សាប្រជុំសម្រេច ក្រុមប្រឹក្សាប្រជុំផ្សះផ្សា និងក្រុមប្រឹក្សាជំនុំជម្រះនៃ គឃ.សប គធ.ខប និង គ.ជ.ប តែប៉ុណ្ណោះ។ រីឯប្រភេទសវនាការដោះស្រាយពាក្យបណ្តឹង គឺមានចែងក្នុងចំណុច ១០.១១.១ នៃ ប.ន.គ.រ។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - មូលហេតុ ៖ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្តឹងតវ៉ា និងជំទាស់នៃបណ្តឹងបោះឆ្នោត ដែលធ្វើឡើងដោយ គឃ.សប គធ.ខប និង គ.ជ.ប មិនមានប្រការ ឬអនុប្រការណាមួយនៃប្រការទាំងនេះ ចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្តឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធារណៈឡើយ។ ការបើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬបើកសវនាការលើបណ្តឹងបោះឆ្នោត គប្បីធ្វើឡើងជាសាធារណៈ និងបើកចំហក្នុងន័យដើម្បីធានាឱ្យមានការចូលរួមសង្កេតឃ្លាំមើលពីអ្នកសង្កេតការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬសាធារណជន និងជាពិសេសភាគីពាក់ព័ន្ធនឹងបណ្តឹង អាចមានសិទ្ធិ និងលទ្ធភាពចូលរួមដោយទូលំទូលាយ ពេញលេញ និងព្រមទាំងធានានូវតម្លាភាព និងភាពត្រឹមត្រូវនៃការដោះស្រាយបណ្តឹងបោះឆ្នោតមួយ។ | |
| ១០.៦.៥ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖ | - **ស្នើសុំបន្ថែម ៖** ក្នុងសេចក្តីព្រាងបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ មានព័ត៌មានពីប្រភេទគឺ៖ ព័ត៌មានដែលចាំបាច់ (ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង, កម្មវត្ថុនៃបណ្តឹង, ប្រភេទនៃអំពើល្មើស និងពេលវេលា ទីកន្លែងប្រព្រឹត្តល្មើស ឬភាពមិនប្រក្រតី)។ យើងអាចកំណត់ថា ជាព័ត៌មានមិនចាំបាច់ដែលត្រូវតែមាន គឺជាព័ត៌មានដែលភ្ជាប់ដោយពាក្យបើអាចធ្វើបាន ឬបើមាន ក្នុងប្រភេទព័ត៌មាននីមួយៗ ឬថាព័ត៌មានទាំងនេះអ្នកប្តឹងមានក្នុងដៃក៏បាន មិនមានក៏បាន)។<br>- មូលហេតុ ៖ រយៈពេលនៃការដាក់ពាក្យបណ្តឹងខ្លីដែលភាគីដើមបណ្តឹងពិបាកក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបានគ្រប់គ្រាន់ ឬព័ត៌មានផ្សេងៗទៀតដែលបទបញ្ជា និងនីតិវិធីមិនបានចាត់ថ្នាក់ជាព័ត៌មានចាំបាច់ត្រូវតែមាន។ លើស | រក្សាទុកដដែល។<br>ខ្លឹមសារនេះ មានន័យគ្រប់គ្រាន់សម្រាប់អនុវត្តហើយ។ ចំពោះព័ត៌មានដែលមានបញ្ជាក់ថា "ប្រសិនបើមាន" នោះគឺអ្នកប្តឹងមិនបាច់បញ្ជាក់ក៏បាន ប្រសិនបើគាត់មិនមាន។ |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | ពីនេះទៅទៀត គឃ/សប ឬ គធ/ខប ឬ គ.ជ.ប ត្រូវបើកការស៊ើបអង្កេត ស្រាវជ្រាវបន្ថែមទៅលើអង្គហេតុ ដើម្បីស្វែងរកការពិតនៅពេលមានបណ្ដឹងណាមួយ។ | |
| ១០.១១ ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិ បណ្ដេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណា ដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង (ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង)។ | - **ស្នើសុំបន្ថែម ៖** ចំណុចនេះ គឺសំដៅលើទម្រង់នៃសេចក្ដីសម្រេច (ទ.១២០៣) គប្បីមានទម្រង់ជាសេក្ដីសម្រេចដែលមានបញ្ជាក់ និងបង្ហាញនូវបំណកស្រាយជាមូលដ្ឋានគតិយុត្តិ និងមូលហេតុដែលមានភាពរឹងមាំ លើការបដិសេធ ឬយល់ព្រមចំពោះបណ្ដឹងបោះឆ្នោតមួយ ឱ្យមានភាពច្បាស់លាស់ អាចទទួលយកបាន និងងាយយល់។<br>- មូលហេតុ ៖ ការបញ្ជាក់នូវទឡ្ហីករណ៍ក្នុងសេចក្ដីសម្រេចឱ្យច្បាស់លាស់ បញ្ជាក់នូវមូលហេតុច្បាស់លាស់ គឺជាមូលដ្ឋានមួយដើម្បីធ្វើឱ្យគូភាគីនៃបណ្ដឹងមានភាពជ្រះស្រឡះក្នុងចិត្ត ក្នុងដំណើរការនៃការដោះស្រាយបណ្ដឹង និងទទួលយកនូវសេចក្ដីសម្រេចដោយតុល្យភាព។ | រក្សាទុកដដែល។<br>ក្រៅពីសម្រង់សេចក្ដីសម្រេច (ទ.១២០៣) គឺនៅមានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ដែលមានទម្រង់ប្រហាក់ប្រហែល នឹងសាលក្រម ឬសាលដីការរបស់តុលាការ ដូចមានចែងក្នុងចំណុច ១០.១១.២១.៥។ ហើយច្បាប់ចតចម្លងនៃសេចក្ដីសម្រេចនេះ អាចផ្ដល់ជូនគូភាគីបាន ប្រសិនបើមានការស្នើសុំ។ |
| ១០.១១.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។ | - **ស្នើសុំបន្ថែម ៖** សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្ដឹងតវ៉ា និងជំទាស់នៃបណ្ដឹងបោះឆ្នោត ដែលធ្វើឡើងដោយ គឃ.សប គធ.ខប គ.ជ.ប <u>ត្រូវមានប្រការ ឬអនុប្រការណាមួយនៃប្រការទាំងនេះ ត្រូវចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្ដឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធារណៈ។</u> ដូចគ្នាដែរ សវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោល ឬនីតិវិធីដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹង ស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលប្រព្រឹត្តទៅដោយ គ.ជ.ប និងស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្ដឹងរបស់ខ្លួន គប្បីធ្វើឡើងជា "សាធារណៈ" ផងដែរ។ | រក្សាទុកដដែល។<br>ជាយុត្តិសាស្ត្រក្នុងការធានាប្រសិទ្ធភាពក្នុងការដោះស្រាយពាក្យបណ្ដឹង បានទាន់ពេលវេលាដែលច្បាប់បានកំណត់ គ.ជ.ប បានបង្កើតរូបមន្តសវនាការ ៣ ប្រភេទ ហើយដែលរូបមន្តនេះ ត្រូវបានប្រើប្រាស់ជាសកល ក្នុងការពិនិត្យ និងដោះស្រាយករណីវិវាទកម្មនៃការបោះឆ្នោត។ ទោះបីជាពាក្យបណ្ដឹង ត្រូវបានដោះស្រាយតាមសវនាការប្រភេទណាមួយក៏ដោយ ក៏រាល់ពាក្យបណ្ដឹងត្រូវបានឆ្លងកាត់នីតិវិធីនៃការស៊ើបអង្កេតស្រាវជ្រាវយ៉ាងហ្មត់ចត់ និងត្រូវបានវិភាគតាមបែបឯកទេស ផ្អែកតាមឯកសារភស្តុតាងប្រភពព័ត៌មាននានា ព្រមទាំងអង្គច្បាប់ពាក់ព័ន្ធ និងត្រូវបានសម្រេចជាចុងក្រោយដោយសមាជិក គ.ជ.ប។ |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| | - មូលហេតុ ៖ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងប្រភេទសវនាការដោះស្រាយបណ្តឹងតវ៉ា និងជំទាស់នៃបណ្តឹងបោះឆ្នោត ដែលធ្វើឡើងដោយ គឃ.សប គធ.ខប និង គ.ជ.ប មិនមានប្រការ ឬអនុប្រការណាមួយនៃប្រការទាំងនេះ ចង្អុលបង្ហាញដល់ ឬតម្រូវឱ្យក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងក្រុមប្រឹក្សាជំនុំជម្រះ បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬត្រូវបើកសវនាការលើបណ្តឹងបោះឆ្នោត ត្រូវធ្វើឡើងជាសាធារណៈឡើយ។ ការបើកការប្រជុំផ្សះផ្សា ឬការបើកប្រជុំសម្រេច ឬបើកសវនាការលើបណ្តឹងបោះឆ្នោត គប្បីធ្វើឡើងជាសាធារណៈ និងបើកចំហក្នុងន័យដើម្បីធានាឱ្យមានការចូលរួមសង្កេតឃ្លាំមើលពីអ្នកសង្កេតការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬសាធារណជន និងជាពិសេសភាគីពាក់ព័ន្ធនឹងបណ្តឹង អាចមានសិទ្ធិ និងលទ្ធភាពចូលរួមដោយទូលំទូលាយ ពេញលេញ និងព្រមទាំងធានានូវតម្លាភាព និងភាពត្រឹមត្រូវនៃការដោះស្រាយបណ្តឹងបោះឆ្នោតមួយ។ | |
| **សំណូមពរ** | | |
| អនុសាសន៍សំខាន់ៗ ដែលមានជាលក្ខណៈទូទៅ | | |
| ១. ពង្រឹងគោលការណ៍សមធម៌ និងតម្លាភាពនៃហិរញ្ញវត្ថុឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ និងការប្រើប្រាស់ធនធានរដ្ឋសម្រាប់សកម្មភាពនយោបាយ។ | | ចំណុចទាំងនេះ គឺជាការសង្ខេបអំពីអនុសាសន៍ជារួមរបស់អង្គការខុមហ្វ្រែលប៉ុណ្ណោះ រីឯអនុសាសន៍ជាក់ស្តែងតាមចំណុចនីមួយៗ ត្រូវបានដាក់បញ្ចូលក្នុងតារាងខាងលើរួចហើយ។<br>ក្រុមការងារសុំមិនឆ្លើយទេ ដើម្បីកុំឱ្យស្ទួន។<br>ក្រុមការងារគ្រាន់តែស្រង់ដើម្បីជូនថ្នាក់ដឹកនាំដើម្បីគោរពជូនជ្រាប។<br>ចំណុចទី៥ គ.ជ.ប អនុវត្តតាមគម្រោង ផែនការសកម្មភាព ដែលបានអនុម័តរួច។ |
| ២. ពង្រឹងអព្យាក្រឹត្យ ឥតលម្អៀងខាងនយោបាយនៃមន្ត្រីកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីតុលាការដែលមានចែងនៅក្នុងក្រមសីលធម៌ ច្បាប់ បទបញ្ញា និងសេចក្តីណែនាំផ្សេងៗ។ | | |
| ៣. ពង្រឹងការផ្តល់កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរជាមួយ គ.ជ.ប តែបន្ថយការជ្រៀតជ្រែក និងឥទ្ធិពលលម្អៀងនយោបាយទៅលើដំណើរការបោះឆ្នោត ពិសេសយុទ្ធនាការឃោសនា និងនៅថ្ងៃបោះឆ្នោតដែលច្បាប់បោះឆ្នោត បទបញ្ញា និងសេចក្តីណែនាំផ្សេងៗទៀតបានកំណត់។ | | |
| ៤. បង្កើតគោលនយោបាយ ឬយន្តការ និងវិធានការ ដើម្បីធានាការអនុវត្តន៍សិទ្ធិចុះឈ្មោះបោះឆ្នោត និងសិទ្ធិបោះឆ្នោតរបស់ពលករចំណាកស្រុកទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។ | | |
| ៥. បន្ថយចំនួនសន្លឹកឆ្នោតបម្រុងនៅត្រឹម ៥% (យ៉ាងច្រើន) នៃប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោត ដែលត្រូវបោះពុម្ព។ | | |
| ៦. ពង្រឹងតម្លាភាពនៃការរាប់សន្លឹកឆ្នោត ដោយមិនត្រូវឱ្យមានការបិទបង្អួច និងទ្វារនៃការិយាល័យរាប់សន្លឹកឆ្នោត។ | | |

| ខ្លឹមសារដើមសេចក្ដីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
|---|---|---|
| ៧. ពង្រឹងការអនុវត្តន៍សេចក្ដីណែនាំ អំពីការរាប់សន្លឹកឆ្នោត ទប់ស្កាត់មន្ត្រីការិយាល័យទាមទារភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ១១០២ និងឯកសារផ្សេងៗទៀតជាមុន នៅពេលមិនទាន់បានបញ្ចប់ការរាប់សន្លឹកឆ្នោត។ ពង្រឹងការយកចិត្តទុកដាក់នៃការសរសេរលទ្ធផល នៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវក្នុងទម្រង់ ទ.១១០២ និងការបិទផ្សាយទម្រង់ ទ.១១០២ និងទម្រង់ ទ.១១០៣ នៅតាមការិយាល័យគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតរួមទាំងបញ្ជាក់លើចំណុចដែលបានលុប ជាពិសេសការប្រើប្រាស់ទឹកលុប។ | | |
| ៨. ជំរុញការចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបច្ចុប្បន្នភាពឯកសារលើបញ្ជីឈ្មោះបោះឆ្នោត និងសំបុត្រកំណើតឱ្យអ្នកមានសិទ្ធិបោះឆ្នោតបានគ្រប់គ្នា ១០០ភាគរយ។ | | |
| **អនុសាសន៍សំខាន់ៗ សម្រាប់សេចក្ដីព្រាង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧** | | |
| ១. នៅក្នុងនីតិវិធីបណ្ដឹង (ចំណុច ១.១០.២៨ នៃប្រការ ១.១០) គ.ជ.ប ត្រូវគ្រប់គ្រង និងមិនគួរឱ្យមានការពង្រីកការអនុវត្តច្បាប់ដែលអនុញ្ញាតឱ្យអាជ្ញាធរយកកំហុសនៃការបំពេញលក្ខខណ្ឌដែលបានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ទៅប្ដឹងទៅតុលាការក្នុងទោសព្រហ្មទណ្ឌនោះទេ ព្រោះថា កំហុសឆ្គង និងបទល្មើសត្រូវបានចែងក្នុងច្បាប់បោះឆ្នោតរួចហើយ។ ការកំណត់ព្រំដែននៃបណ្ដឹង គឺជាវិធានមួយដែលអាចជួយកាត់បន្ថយបញ្ហាបដិវាទ (Controversy) អំពីការដាក់ទោសសិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពក្នុងជីវភាពនយោបាយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងការបកស្រាយដោយទូលំទូលាយ។ | | |
| ២. ការកំណត់បិទការទទួលពាក្យស្នើសុំចុះឈ្មោះអ្នកសង្កេតការណ៍ (ប្រការ ៣.៣) ស្នើ គ.ជ.ប កែសម្រួលពេលវេលាចាប់ពីការទទួលពាក្យចាប់ផ្ដើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោត រហូតដល់ ៣(បី) ថ្ងៃមុនថ្ងៃបោះឆ្នោត ព្រោះថា ដើម្បីសម្រួលឱ្យសមាគម ឬអង្គការមានពេលវេលាបន្ថែមទៀតក្នុងការជ្រើសរើសអ្នកសង្កេតការណ៍របស់ខ្លួន និងស្នើឱ្យដំណើរការទទួលពាក្យអនុវត្តនៅត្រឹម គធ.ខប ព្រោះការសម្រេចផ្ដល់កាតអ្នកសង្កេតការណ៍ត្រឹម គធ.ខប វាបានកាត់បន្ថយការងារបន្ទុកច្រើននៅ គ.ជ.ប និងពន្លឿននូវការចេញកាតឱ្យទាន់ពេលថែមទៀត។ | | |
| ៣. ស្នើលុបឃ្លាក្នុងប្រការ ៧.៨ ដែលបានអនុញ្ញាតឱ្យ <u>កងកម្លាំងប្រដាប់អាវុធគ្រប់ និងមន្ត្រីតុលាការ</u> ចូលរួមសកម្មភាពឃោសនាគាំទ្រដល់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ព្រោះថា កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីតុលាការ ជាភាគីសំខាន់ចូលរួមរក្សាសន្តិសុខ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋដែលពួកគេត្រូវធ្វើកិច្ចការសម្រាប់ដោះស្រាយឱ្យប្រជាពលរដ្ឋជាចាំបាច់។ ម្យ៉ាងទៀត នីតិវិធី ត្រូវផ្អែកឱ្យស្របជាមួយច្បាប់របស់ស្ថាប័នដែលបានចែងពីសកម្មភាពអព្យាក្រឹតរបស់ស្ថាប័នសាម៉ីនោះ និងក៏ត្រូវមានសមសភាពឱ្យស្របជាមួយការចែងក្នុងចំណុចភាពឥតលម្អៀងនៃអង្គការសង្គមស៊ីវិលផងដែរ ក្នុងការរក្សាជំហសកម្មភាពឥតលម្អៀង។ | | |
| ៤. គ.ជ.ប ត្រូវបន្ថែមភាពលម្អិត ឬចែងពិសេស (ក្នុងប្រការ៨.៥) ត្រូវចែងឱ្យមានការបើកចំហទ្វាររបងនៃបរិវេណទីតាំងការិយាល័យបោះឆ្នោត បើកចំហបង្អួច និងទ្វារនៃការិយាល័យរាប់សន្លឹកឆ្នោត បើសិនជាទីនោះមិនមានបញ្ហាអសន្តិសុខទេនោះ ព្រោះថា ដើម្បីពង្រឹងតម្លាភាពនៃការរាប់សន្លឹកឆ្នោត និងកាត់បន្ថយភាពមិនប្រក្រតីនៃការរាប់សន្លឹកឆ្នោត ជាពិសេសភាពមន្ទិលរបស់ម្ចាស់ឆ្នោត។ | | |

| ខ្លឹមសារដើមសេចក្តីព្រាង ប.ន.ត.រ | យោបល់ស្នើសុំកែសម្រួល និងមូលហេតុ | ការសម្រេចរបស់ គ.ជ.ប |
| --- | --- | --- |
| ៥. ពង្រឹងនីតិវិធីបន្ថែម(ក្នុងចំណុច១.១០.១ នៃប្រការ១.១០)ឱ្យបានច្បាស់ក្នុងការទប់ស្កាត់សកម្មភាពទាំងឡាយ ដែលនាំឱ្យមានការភ័ន្តច្រឡំ ឬបង្កើតការព្រួយបារម្ភ ឬនឹងនាំឱ្យភិតភ័យដល់អ្នកបោះឆ្នោតពីជនដែលគ្មានភារកិច្ច ឬមិនតម្រូវដោយនីតិវិធីបោះឆ្នោត ពិសេសវត្តមានរបស់មន្ត្រីអាជ្ញាធរមូលដ្ឋាន ក្នុងការស្ទាក់ហៅ អ្នកបោះឆ្នោតមកកត់ឈ្មោះ ឬការប្រើពាក្យសម្តី នៅខាងក្នុង ឬក្រៅបរិវេណ និងនៅតាមដងផ្លូវនៃភូមិ ព្រោះថា ការកត់ឈ្មោះ ឬការប្រើពាក្យសម្តីពីជនដែលមិនមានតួនាទីក្នុងដំណើរការបោះឆ្នោត វាបានបង្កឱ្យមានការព្រួយបារម្ភចំពោះប្រជាពលរដ្ឋ ក្នុងការបញ្ជាប្រឈមលើការសម្រេចឆន្ទៈរបស់ម្ចាស់ឆ្នោតក្នុងការបោះឆ្នោត។ | |
| ៦. គ.ជ.ប ត្រូវមានវិធានការពង្រឹងក្នុងចំណុច៨.១០.៩, ៨.១០.១៤ ក្នុងប្រការ៨.១០ ប្រការ៨.១២ និងចំណុច៨.២០.៦ នៃប្រការ៨.២០ ការអនុវត្តសេចក្តីណែនាំ អំពីការរាប់សន្លឹកឆ្នោត ដោយទប់ស្កាត់នូវការអនុវត្តសកម្មភាពរបស់មន្ត្រីការិយាល័យទាមទារឱ្យមានភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ចុះហត្ថលេខាលើតារាងកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ ) ជាមុន នៅពេលមិនទាន់បានបញ្ចប់ការរាប់សន្លឹកឆ្នោតនូវឡើយ និងពង្រឹងការយកចិត្តទុកដាក់ក្នុងការសរសេរលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវនៅក្នុងទម្រង់ ១១០៨ និងទម្រង់ ១១០២ និងការបិទផ្សាយ ទ.១១០២ និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) នៅតាមការិយាល័យគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត ព្រោះថាការពង្រឹងនេះ គឺដើម្បីភាពត្រឹមត្រូវនៃការកត់ត្រា និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដើម្បីឱ្យប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធងាយស្រួលក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការរាប់សន្លឹកឆ្នោត។ | |
| ៧. នីតិវិធីគួរតែបន្ថែមឃ្លាថា... ទ.១១០២ ត្រូវផ្តល់ជូនដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយនៅការិយាល័យ និងនៅ គឃ.សប (ក្នុងចំណុច៨.១៣.៤ នៃប្រការ៨.១៣) ព្រោះថាអ្នកសង្កេតការណ៍ក៏ជាភាគីចូលរួមជាសក្សីក្នុងការអនុវត្តរបស់ភាគីពាក់ព័ន្ធផងដែរ។ បន្ថែមលើប្រការនេះ គ.ជ.ប ត្រូវចែងពីទោសទណ្ឌឱ្យបានតឹងរឹងផងដែរដល់មន្ត្រីដែលទទួលខុសត្រូវក្នុងការអនុវត្តការងារនឹងរំលោភលើសេចក្តីណែនាំនេះ ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្ត និងការទទួលខុសត្រូវ។ | |

ថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២